**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ:៣៤.អនក្រ.បក**

# អនុក្រឹត្យ
# ស្តីពី
# ការកែប្រែនិងការដំឡើងប្រាក់បំណាច់មុខងារមន្ត្រីពន្ធនាគារក្រសួងមហាផ្ទៃ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២១១/០២១ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីពន្ធនាគារ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២១៩/០២៥ ចុះថ្ងៃទី២០ ខែធ្នូ ឆ្នាំ២០១៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០២០
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨១៣/៨៩២ ចុះថ្ងៃទី០៧ ខែសីហា ឆ្នាំ២០១៣ ស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌមន្ត្រីពន្ធនាគារក្រសួងមហាផ្ទៃ
- បានឃើញអនុក្រឹត្យលេខ២០២ អនក្រ.បក ចុះថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០១៤ ស្តីពីការកំណត់សមមូលឋានន្តរសក្តិមន្ត្រីពន្ធនាគារ ជាមួយនឹងឋានន្តរសក្តិមន្ត្រីរាជការស៊ីវិល និងឋានន្តរសក្តិមន្ត្រីនគរបាលជាតិ និងការធ្វើសមាហរណកម្មទៅក្នុងក្របខ័ណ្ឌមន្ត្រីពន្ធនាគារក្រសួងមហាផ្ទៃ
- បានឃើញអនុក្រឹត្យលេខ៣៨ អនក្រ.បក ចុះថ្ងៃទី១៨ ខែមីនា ឆ្នាំ២០១៥ ស្តីពីការកំណត់និងការបើកផ្តល់បៀវត្សមូលដ្ឋាន ប្រាក់បន្ទាប់បន្សំនៃបៀវត្ស និងរបបឧបត្ថម្ភផ្សេងៗជូនមន្ត្រីពន្ធនាគារក្រសួងមហាផ្ទៃ
- បានឃើញអនុក្រឹត្យលេខ១០៩ អនក្រ.បក ចុះថ្ងៃទី១៩ ខែសីហា ឆ្នាំ២០១៥ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងមហាផ្ទៃ



Media from www.moj.gov.kh resource from www.ocm.gov.kh

- បានឃើញអនុក្រឹត្យលេខ៥៩ អនក្រ.បក ចុះថ្ងៃទី០១ ខែមេសា ឆ្នាំ២០១៦ ស្តីពីការកែសម្រួល និងការដំឡើងប្រាក់បំណាច់មុខងារជូនមន្ត្រីពន្ធនាគារក្រសួងមហាផ្ទៃ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និង រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ

**សម្រេច**

**មាត្រា១ .-**

ប្រាក់បំណាច់មុខងារមន្ត្រីពន្ធនាគារក្រសួងមហាផ្ទៃ ត្រូវបានកែប្រែនិងដំឡើងដូចខាងក្រោម៖

| ល.រ | បរិយាយ | ប្រាក់បំណាច់មុខងារ(រៀល) |
|---|---|---|
| ១ | អគ្គនាយក | ១ ៨៣០ ០០០ |
| ២ | អគ្គនាយករង | ១ ៤៨០ ០០០ |
| ៣ | ប្រធាននាយកដ្ឋាន | ៨៤០ ០០០ |
| ៤ | អនុប្រធាននាយកដ្ឋាន<br>ប្រធានមណ្ឌលអប់រំកែប្រែ<br>ប្រធានពន្ធនាគាររាជធានី ខេត្ត | ៧៧០ ០០០ |
| ៥ | ប្រធានការិយាល័យថ្នាក់កណ្តាល<br>អនុប្រធានមណ្ឌលអប់រំកែប្រែ<br>អនុប្រធានពន្ធនាគាររាជធានី ខេត្ត | ៦៤០ ០០០ |
| ៦ | អនុប្រធានការិយាល័យថ្នាក់កណ្តាល<br>ប្រធានការិយាល័យមណ្ឌលអប់រំកែប្រែ<br>ប្រធានការិយាល័យពន្ធនាគាររាជធានី ខេត្ត | ៥៧០ ០០០ |
| ៧ | ប្រធានផ្នែកថ្នាក់កណ្តាល<br>អនុប្រធានការិយាល័យមណ្ឌលអប់រំកែប្រែ<br>អនុប្រធានការិយាល័យពន្ធនាគាររាជធានី ខេត្ត | ៥១០ ០០០ |
| ៨ | អនុប្រធានផ្នែកថ្នាក់កណ្តាល<br>ប្រធានផ្នែកមណ្ឌលអប់រំកែប្រែ<br>ប្រធានផ្នែកពន្ធនាគាររាជធានី ខេត្ត | ៤៧០ ០០០ |
| ៩ | នាយត្រួតថ្នាក់កណ្តាល<br>អនុប្រធានផ្នែកមណ្ឌលអប់រំកែប្រែ<br>អនុប្រធានផ្នែកពន្ធនាគាររាជធានី ខេត្ត | ៤៥០ ០០០ |
| ១០ | នាយត្រួតរងថ្នាក់កណ្តាល<br>ប្រធានក្រុមមណ្ឌលអប់រំកែប្រែ<br>ប្រធានក្រុមពន្ធនាគាររាជធានី ខេត្ត | ៤៤៥ ០០០ |
| ១១ | អនុប្រធានក្រុមមណ្ឌលអប់រំកែប្រែ<br>អនុប្រធានក្រុមពន្ធនាគាររាជធានី ខេត្ត | ៤៤០ ០០០ |
| ១២ | មន្ត្រីពន្ធនាគារ | ៤១០ ០០០ |

**មាត្រា២ .-**

ប្រាក់បំណាច់មុខងារខាងលើ ត្រូវអនុវត្តចាប់ពីថ្ងៃទី០១ ខែមេសា ឆ្នាំ២០២០ តទៅ។



Media from www.moj.gov.kh resource from www.ocm.gov.kh

**មាត្រា៣ .-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ ចន្ទ ៨ រោច ខែ ផល្គុន ឆ្នាំ កុរ ឯកស័ក ព.ស.២៥៦៣

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៦ ខែ មីនា ឆ្នាំ២០២០

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីគោរពជម្រាបជូន

សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី សូមហត្ថលេខា

| **ឧបនាយករដ្ឋមន្ត្រី<br>រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ** | **ឧបនាយករដ្ឋមន្ត្រី<br>រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ** | **រដ្ឋមន្ត្រី<br>ក្រសួងមុខងារសាធារណៈ** |
|---|---|---|
| **សម្តេចក្រឡាហោម ស ខេង** | **អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន** | **ពេជ្រ ប៊ុនធិន** |

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា៣
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ



Media from www.moj.gov.kh resource from www.ocm.gov.kh